ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣៨១ ប្រក.កសក.ប

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាន និងវិទ្យាស្ថាននៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨/ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីបានរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០

- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- យោងលិខិតលេខ២១០១ មស.នក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈស្តីពីការឯកភាពលើការរៀបចំប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាននិងវិទ្យាស្ថាននៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១.-**

អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ មាននាយកដ្ឋានចំណុះចំនួន០៤ និងវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ ចំនួន០១ មានថ្នាក់ស្មើនាយកដ្ឋានដូចខាងក្រោម៖

១-នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការ

២-នាយកដ្ឋានផលិតកម្មសត្វ

៣-នាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល

៤-នាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម

៥-វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ។

អង្គការលេខរបស់នាយកដ្ឋាន និងវិទ្យាស្ថាន ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២.-**

នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការ មានការិយាល័យចំណុះចំនួន០៥ ដូចខាងក្រោម៖

១-ការិយាល័យរដ្ឋបាល និងបុគ្គលិក

២-ការិយាល័យគណនេយ្យ

៣-ការិយាល័យផែនការ និងស្ថិតិ

៤-ការិយាល័យសហប្រតិបត្តិការ

៥-ការិយាល័យតាមដាន និងវាយតម្លៃ។

ការិយាល័យនីមួយៗ មានតួនាទីភារកិច្ច ដូចខាងក្រោម៖

**២.១-ការិយាល័យរដ្ឋបាល និងបុគ្គលិក ៖**

- សម្របសម្រួលរាល់សកម្មភាពការងាររដ្ឋបាល និងសង្គមរបស់អគ្គនាយកដ្ឋាន

- សម្របសម្រួលរៀបចំលិខិតបញ្ញាបេសកកម្ម ឯកសារពាក់ព័ន្ធ និងធ្វើសំយោគលើខ្លឹមសារលិខិតស្នាមមុនដាក់ចូលថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន
- ថែរក្សាទុកដាក់ចងក្រងឯកសារចេញ-ចូលតាមលំដាប់ថ្នាក់លិខិតស្នាម និងប្រភេទ
- ទំនាក់ទំនងការងារ និងសម្របសម្រួលកិច្ចការដែលទាក់ទងទៅនឹងការរៀបចំទម្រង់បែបបទលិខិតស្នាមទូទៅរបស់អគ្គនាយកដ្ឋាន
- ទទួលរបាយការណ៍បណ្តាការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត និងអង្គភាពនានាពាក់ព័ន្ធ ធ្វើការបែងចែកចង្អោមព័ត៌មានជូននាយកដ្ឋានជំនាញ និងវិទ្យាស្ថាន ដើម្បីការវិភាគ និងរៀបចំរបាយការណ៍បច្ចេកទេស
- គ្រប់គ្រងគេហទំព័ររបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- ដកស្រង់របាយការណ៍សកម្មភាពសំខាន់ៗរបស់នាយកដ្ឋាន វិទ្យាស្ថាន និងថ្នាក់ដឹកនាំនាយកដ្ឋាន ដើម្បីរាយការណ៍ជូនអគ្គនាយកនៅរាល់ពេលប្រជុំប្រចាំខែ និងចូលរួមធ្វើកំណត់ហេតុ
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យសម្រាប់មាតិកាសំណុំឯកសារផ្សេងៗ
- រៀបចំកិច្ចប្រជុំ ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រង និងថែទាំ ជួសជុលសម្ភារ ឧបករណ៍ បរិក្ខា មធ្យោបាយ បម្រើឲ្យនាយកដ្ឋានវិទ្យាស្ថាន និងថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន
- លើកសំណើ បែងចែក ប្រើប្រាស់ប្រេងឥន្ធនៈ មធ្យោបាយសម្រាប់បណ្តាអង្គភាពចំណុះអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- ការពារសន្តិសុខសណ្តាប់ធ្នាប់ និងអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់អគ្គនាយកដ្ឋាន
- តាមដានលិខិតចេញ ចូល អនុញ្ញាត និងសំណើនានា នៃការធ្វើអាជីវកម្មសត្វ ផលិតផលសត្វ និងលិខិតអនុញ្ញាតផ្សេងទៀតទាក់ទងភារកិច្ចនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- រៀបចំលិខិតរដ្ឋបាលសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការ ការដំឡើងឋានៈ ការដំឡើងកាំប្រាក់ ការសរសើរ ការសម្រួលភារកិច្ច ការដាក់ពិន័យ ការលុបឈ្មោះ និងការដាក់ឲ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស
- ធ្វើបច្ចុប្បន្នភាពស្ថិតិ បញ្ជីឈ្មោះមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា រៀបចំសំណុំលិខិតដាក់ឲ្យមន្ត្រីរាជការចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ និងលើកសំណើសុំប្រាក់ឧបត្ថម្ភ និងរបបធានារ៉ាប់រងសង្គម
- រៀបចំកសាងផែនការតម្រូវការមន្ត្រីរាជការប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- សិក្សា ស្រាវជ្រាវ លើកសំណើ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំនាយកដ្ឋានពាក់ព័ន្ធការរៀបចំរចនាសម្ព័ន្ធ ចំនួនមន្ត្រីរាជការ មុខងារភារកិច្ចស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានពាក់ព័ន្ធ
- រៀបចំគម្រោងផែនការតម្រូវការមន្ត្រីរាជការ និងគោលការណ៍ណែនាំសម្រាប់អភិវឌ្ឍន៍ធន-

ធានមនុស្ស និងធ្វើវិភាគលើតម្លាតនៃការបណ្តុះបណ្តាលធនធានមនុស្សនៃអគ្គនាយកដ្ឋាន

- សម្របសម្រួលជាមួយអង្គភាពចំណុះអគ្គនាយកដ្ឋាន អង្គការជាតិ អន្តរជាតិ វិស័យឯក-ជន និងភ្នាក់ងារពាក់ព័ន្ធលើការងារអភិវឌ្ឍន៍ធនធានមនុស្ស
- ពិនិត្យ និងលើកសំណើបញ្ជូនមន្ត្រីទៅធ្វើវិក្រឹតការ សុក្រឹតការ ឬបន្តការសិក្សានៅក្នុង និងក្រៅប្រទេសសម្រាប់រយៈពេលខ្លី មធ្យម វែង និងចូលរួមប្រជុំ សិក្ខាសាលា ទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

២.២-ការិយាល័យគណនេយ្យ ៖

- ជំរុញការអនុវត្តបទប្បញ្ញត្តិ សេចក្តីសម្រេច និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធកិច្ចការគណនេយ្យ និងហិរញ្ញវត្ថុ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារបរិក្ខាររបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- គ្រប់គ្រង ថែរក្សា និងតម្កល់ទុកនូវរាល់ឯកសារហិរញ្ញវត្ថុស្របតាមគោលការណ៍ណែនាំនានា
- សម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធរាល់ការងារត្រួតពិនិត្យបិទបញ្ជីគណនេយ្យ និងជម្រះបញ្ជីគណនេយ្យ និងការធ្វើសវនកម្មហិរញ្ញវត្ថុ
- សហការលើកគម្រោង និងរៀបចំផែនការចំណូល-ចំណាយប្រចាំឆ្នាំ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- រៀបចំផែនការ និងរបាយការណ៍ចំណូល-ចំណាយប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- គ្រប់គ្រងបេឡាសាច់ប្រាក់ និងការងារអាណត្តិកិច្ចរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- ធ្វើគម្រោងផែនការឥណទានបៀវត្ស ឥណទាននិវត្តន៍ជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

២.៣-ការិយាល័យផែនការ និងស្ថិតិ ៖

- សហការរៀបចំកសាងគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងវិនិយោគសាធារណៈ ព្រមទាំងលើកទិសដៅអនុវត្តសម្រាប់ការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វ
- ពិនិត្យ និងផ្តល់យោបល់ពាក់ព័ន្ធផែនការថវិកាកម្មវិធី និងការអនុវត្តចង្កោមសកម្មភាពរបស់អង្គភាពចំណុះអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- សម្របសម្រួលការងារផែនការ កសាងសមត្ថភាព និងពង្រឹងជំនាញដល់មន្ត្រីផែនការនៃអង្គភាពពាក់ព័ន្ធចំណុះអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- រៀបចំវិធីសាស្ត្រនៃប្រព័ន្ធស្ថិតិពាក់ព័ន្ធសុខភាពសត្វ និងផលិតកម្មសត្វ
- រៀបចំការគ្រប់គ្រង ការអនុវត្តធ្វើជំរឿន ធ្វើអង្កេត និងធ្វើការប្រមូលព័ត៌មានតាមរបាយការណ៍

រដ្ឋបាល ដោយសហការយ៉ាងជិតស្និតជាមួយអង្គភាពជំនាញមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត

- ទំនាក់ទំនង សហការយ៉ាងជិតស្និទ្ធជាមួយស្ថិតិនៃស្ថាប័នរដ្ឋ អង្គការជាតិ អន្តរជាតិ ក្រុមហ៊ុនឯកជន និងបណ្តាស្ថិតិពាក់ព័ន្ធផ្សេងៗទៀតធ្វើឲ្យព័ត៌មាន និងទិន្នន័យស្ថិតិវិស័យសុខភាពសត្វ និងផលិតកម្មសត្វទទួលបានលទ្ធផលល្អ
- សម្របសម្រួលការងារស្ថិតិ កសាងសមត្ថភាព និងពង្រឹងជំនាញដល់មន្ត្រីអនុវត្តស្ថិតិនៃអង្គភាពពាក់ព័ន្ធចំណុះអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- ធ្វើរបាយការណ៍ស្ថិតិប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំអំពីសកម្មភាពលទ្ធផល ការងារអនុវត្តផែនការ និងលើកទិសដៅសម្រាប់រយៈពេលខ្លី មធ្យម និងវែង
- តម្កល់ទុកដាក់ ថែរក្សាឯកសារ និងគ្រប់គ្រងបណ្ណាល័យរបស់អគ្គនាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

**២.៤-ការិយាល័យសហប្រតិបត្តិការ ៖**

- សម្របសម្រួល និងជំរុញកិច្ចការសាធារណៈជាមួយអង្គការជាតិ អន្តរជាតិ ភ្នាក់ងារអភិវឌ្ឍន៍ ដៃគូអភិវឌ្ឍន៍ សមាគម សហគមន៍ ដែលធ្វើការពាក់ព័ន្ធសុខភាពសត្វ និងផលិតកម្មសត្វ
- សម្របសម្រួល និងជំរុញការងារកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន អង្គការពាណិជ្ជកម្មពិភពលោក អង្គការសុខភាពសត្វពិភពលោក អង្គការស្បៀង និងកសិកម្មពិភពលោក និងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីនានា
- ចូលរួមពិនិត្យ ផ្តល់យោបល់ និងរៀបចំអនុស្សារណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង ឬឯកសារលិខិតទំនាក់ទំនងផ្សេងៗ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ
- ចងក្រង គ្រប់គ្រងទិន្នន័យ និងឯកសារដែលពាក់ព័ន្ធទៅនឹងការងារកិច្ចសហប្រតិបត្តិការ
- សម្របសម្រួលការរៀបចំគម្រោងនានា សម្រាប់កម្មវិធីអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ
- សរុបរបាយការណ៍ការងារសហប្រតិបត្តិការប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

**២.៥-ការិយាល័យតាមដាន និងវាយតម្លៃ ៖**

- តាមដានជាប្រចាំរាល់ប្រតិបត្តិការហិរញ្ញវត្ថុរបស់បណ្តាអង្គភាពចំណុះអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- វិភាគព័ត៌មាន ទិន្នន័យស្ថិតិ វាយតម្លៃប៉ាន់ស្មាន និងព្យាករណ៍ចំពោះលទ្ធផលដែលទទួលបានពីការវិវត្តន៍ឡើងចុះក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ និងសិក្សាវិភាគការវិវត្តន៍នៃសេដ្ឋកិច្ចសង្គមពាក់ព័ន្ធសុខភាពសត្វ និងផលិតកម្មសត្វ
- ប្រៀបធៀបគម្រោងផែនការប្រចាំឆ្នាំរបស់អង្គភាពជំនាញនីមួយៗ ទៅនឹងលទ្ធផលសម្រេចបាននាបំណាច់ឆ្នាំ រួចវាយតម្លៃ
- សហការ តាមដាន ស្រាវជ្រាវអំពីតម្លៃសត្វ សាច់ ផលិតផលមានដើមកំណើតពីសត្វក្នុងស្រុក និងអន្តរជាតិ

- តាមដានជំរុញ និងវាយតម្លៃការអនុវត្តន៍គម្រោងថវិកាតាមកម្មវិធី អនុកម្មវិធី និងគម្រោងសហប្រតិបត្តិការផ្សេងៗទៀតតាមបណ្តាអង្គភាពចំណុះអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- តាមដាន និងវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍វិស័យសុខភាពសត្វ និងផលិតកម្មសត្វ
- សិក្សាស្រាវជ្រាវអំពីការអភិវឌ្ឍទីផ្សារផលិតកម្មសត្វ ប្រសិទ្ធភាព និងផលប៉ះពាល់លើជីវភាពរស់នៅរបស់ប្រជាជន
- សហការ តាមដាន ស្រាវជ្រាវការចិញ្ចឹមសត្វ កំណើន ថយចុះ ស្ថានភាពជំងឺសត្វ និងផលប៉ះពាល់ផ្សេងៗទៀត
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

**ប្រការ៣ ..**

នាយកដ្ឋានផលិតកម្មសត្វ មានការិយាល័យចំណុះចំនួន០៦ ដូចខាងក្រោម៖

១-ការិយាល័យអភិវឌ្ឍន៍ការចិញ្ចឹមសត្វ

២-ការិយាល័យគ្រប់គ្រងផលិតកម្មចំណីសត្វ

៣-ការិយាល័យពូជសត្វ និងសេនេទិកសត្វ

៤-ការិយាល័យគ្រប់គ្រងកាកសំណល់សត្វ

៥-ការិយាល័យគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ

៦-ការិយាល័យអត្តសញ្ញាណកម្មសត្វ ។

ការិយាល័យនីមួយៗ មានតួនាទីភារកិច្ច ដូចខាងក្រោម ៖

៣.១-ការិយាល័យអភិវឌ្ឍន៍ការចិញ្ចឹមសត្វ ៖

- ចូលរួមរៀបចំផែនការអភិវឌ្ឍន៍ ការគ្រប់គ្រងនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការចិញ្ចឹមសត្វ
- រៀបចំផែនការ សកម្មភាព គម្រោងថវិកាទាក់ទងការអភិវឌ្ឍការចិញ្ចឹមសត្វ
- ស្រាវជ្រាវ រៀបចំចងក្រងឯកសារបច្ចេកទេស និងបទពិសោធន៍ថ្មីៗទាក់ទងការចិញ្ចឹមសត្វ
- ប្រមូល វិភាគ ចងក្រងទិន្នន័យ ជំរឿន ស្រង់ស្ថិតិសត្វគ្រប់ប្រភេទ និងគ្រប់គ្រងថែរក្សាទិន្នន័យស្ថិតិសត្វ
- សិក្សាស្រាវជ្រាវ និងកំណត់តំបន់សក្តានុពលសម្រាប់អភិវឌ្ឍន៍ការចិញ្ចឹមសត្វ
- រៀបចំពិធីសារ និងជំរុញការអនុវត្តបច្ចេកទេសចិញ្ចឹមសត្វ និងបទដ្ឋានបច្ចេកទេសសុខុមាលភាពសត្វ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តការចិញ្ចឹមសត្វ
- សហការ សម្របសម្រួលក្នុងការបង្កើត និងកិច្ចដំណើរការសហគមន៍ចិញ្ចឹមសត្វ
- សិក្សា រៀបចំ កំណត់ពីតម្រូវការបណ្តុះបណ្តាលការចិញ្ចឹមសត្វ និងវាយតម្លៃការបណ្តុះបណ្តាល
- បណ្តុះបណ្តាលបច្ចេកទេសផលិតកម្មសត្វដល់អ្នកពាក់ព័ន្ធ
- គ្រប់គ្រង តាមដាន ផ្តល់សេវា និងប្រឹក្សាយោបល់លើការងារចិញ្ចឹមសត្វ

- ស្រាវជ្រាវ រៀបចំចងក្រង ផ្សព្វផ្សាយព័ត៌មានផលិតកម្មសត្វ ទីផ្សារនិងតម្លៃសត្វ ផលិតផលសត្វ និងសម្ភារបម្រើឲ្យផលិតកម្មសត្វ
- សិក្សាស្រាវជ្រាវពីសក្តានុពល សេចក្តីត្រូវការ ការផ្គត់ផ្គង់សត្វ និងផលិតផលសត្វ
- រៀបចំរបាយការណ៍សកម្មភាពការងារជូននាយកដ្ឋាន តាមគោលការណ៍កំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

៣.២-ការិយាល័យគ្រប់គ្រងផលិតកម្មចំណីសត្វ ៖

- ចូលរួមរៀបចំផែនការអភិវឌ្ឍន៍ ការគ្រប់គ្រង និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រង និងផលិតកម្មចំណីសត្វ
- រៀបចំផែនការ សកម្មភាព គម្រោងថវិកា ទាក់ទងការគ្រប់គ្រង និងផលិតកម្មចំណីសត្វ
- ស្រាវជ្រាវ រៀបចំចងក្រងឯកសារបច្ចេកទេស និងបទពិសោធន៍ថ្មីៗទាក់ទងការគ្រប់គ្រង និងផលិតកម្មចំណីសត្វ
- ប្រមូល វិភាគ ចងក្រងទិន្នន័យ ជំរឿន ស្រង់ស្ថិតិ កន្លែងផលិត និងលាយផ្សំចំណីសត្វ កន្លែងស្តុក កន្លែងលក់ចែកចាយចំណីសត្វ និងមន្ទីរពិសោធន៍វិភាគចំណីសត្វ និងគ្រប់គ្រងថែរក្សាទិន្នន័យពាក់ព័ន្ធការគ្រប់គ្រង និងផលិតកម្មចំណីសត្វ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃទីកន្លែងផលិត និងលាយផ្សំចំណីសត្វ កន្លែងស្តុក កន្លែងលក់ចែកចាយចំណីសត្វ
- សហការ វាយតម្លៃការបង្កើត និងគ្រប់គ្រងមន្ទីរពិសោធន៍វិភាគចំណីសត្វ
- សហការរៀបចំបមាណីយចំណីសត្វ និងបទដ្ឋានបច្ចេកទេសចំណីសត្វ
- ត្រួតពិនិត្យកម្រិតបមាណីយ គុណភាព ប្រសិទ្ធភាព ការផលិត ការវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មាន ចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែមសម្រាប់លាយផ្សំចំណីសត្វ
- ពិនិត្យ ផ្តល់យោបល់ ក្នុងការអនុញ្ញាតបង្កើតកន្លែងផលិត និងលាយផ្សំចំណីសត្វ កន្លែងស្តុក កន្លែងលក់ចែកចាយចំណីសត្វ និងសារធាតុលាយផ្សំចំណីសត្វ
- ពិនិត្យ ផ្តល់យោបល់ក្នុងការចេញវិញ្ញាបនបត្រផលិតកម្មល្អប្រសើរ គុណភាព សុវត្ថិភាព និងប្រសិទ្ធភាពចំណីសត្វនិងសារធាតុលាយផ្សំចំណីសត្វ
- ពិនិត្យ និងផ្តល់យោបល់ក្នុងការអនុញ្ញាតលើការនាំចូល នាំចេញ នាំឆ្លងកាត់ ចំណីសត្វ និងវត្ថុធាតុដើមផ្សំចំណីសត្វ
- អនុវត្តការធ្វើបង្ហាញពីបច្ចេកទេសផលិត លាយផ្សំចំណីសត្វ និងដំណាំចំណីសត្វ
- ចូលរួមពិសោធន៍ ត្រួតពិនិត្យ និងវាយតម្លៃនៅទីវាលលើគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពចំណីសត្វ និងសារធាតុលាយផ្សំចំណីសត្វ
- ស្រាវជ្រាវ ចងក្រង និងបណ្តុះបណ្តាលបច្ចេកទេសស្តីពីការផលិតលាយផ្សំចំណីសត្វ កែច្នៃចំណីសត្វ ការដាំដំណាំចំណីសត្វ និងការផ្តល់ចំណីសត្វ
- ណែនាំ ផ្តល់សេវា និងប្រឹក្សាយោបល់លើការងារផលិត លាយផ្សំចំណីសត្វ និងដំណាំចំណីសត្វ

- រៀបចំរបាយការណ៍សកម្មភាពការងារជូននាយកដ្ឋាន តាមគោលការណ៍កំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

**៣.៣-ការិយាល័យពូជសត្វ និងសេនេទិកសត្វ ៖**

- រៀបចំផែនការអភិវឌ្ឍន៍ ការគ្រប់គ្រង និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការងារជ្រើស-រើសបង្កាត់ពូជសត្វ និងគ្រប់គ្រងសេនេទិកសត្វ
- រៀបចំផែនការ សកម្មភាព គម្រោងថវិកា ទាក់ទងការងារបង្កាត់ និងជ្រើសរើសពូជសត្វ និងគ្រប់គ្រងសេនេទិកសត្វ
- ចូលរួមស្រាវជ្រាវ រៀបចំចងក្រងឯកសារបច្ចេកទេស និងបទពិសោធន៍ថ្មីៗទាក់ទងការ-ងារ ជ្រើសរើស បង្កាត់ពូជសត្វ និងគ្រប់គ្រងសេនេទិកសត្វ
- គ្រប់គ្រង ត្រួតពិនិត្យ តាមដាន វាយតម្លៃទីកន្លែងបង្កាត់ពូជសត្វ ផ្តល់សេវាកម្មបង្កាត់ពូជ និងការអនុវត្តស្តីពីការអនុវត្តចិញ្ចឹមសត្វល្អប្រសើរ (GAHP)
- ពិនិត្យ តាមដាន និងវាយតម្លៃលើគុណភាព និងប្រសិទ្ធភាពនៃការងារបង្កាត់ពូជសត្វ
- គ្រប់គ្រងធនធានសេនេទិកសត្វ តាមរយៈវិធានការអភិរក្សពូជសត្វជាតិ
- ចូលរួមពិសោធស្រាវជ្រាវ និងផ្សព្វផ្សាយលើការចិញ្ចឹមសត្វ និងការបង្កាត់ពូជសត្វតាមបច្ចេកវិទ្យាទំនើប
- ពិនិត្យ និងផ្តល់យោបល់ក្នុងការអនុញ្ញាតធ្វើអាជីវកម្ម ផ្តល់លិខិតអនុញ្ញាតនាំចូល នាំចេញ និងនាំឆ្លងកាត់ពូជសត្វ ឬផលិតផលពូជសត្វ ឬបង្កើតពូជថ្មីនៃសត្វ ក្នុងទម្រង់ជាសត្វរស់ ឬរូបធាតុសេនេទិកសត្វ
- រៀបចំចុះបញ្ជី និងផ្តល់វិញ្ញាបនបត្របញ្ជាក់ពូជសត្វ
- រៀបចំបង្កើត និងធ្វើបច្ចុប្បន្នភាពបញ្ជីពូជសត្វ
- ណែនាំ ផ្តល់សេវា និងប្រឹក្សាយោបល់លើការងារជ្រើសរើស និងបង្កាត់ពូជសត្វ និងការបង្កើតទីកន្លែងបង្កាត់ពូជសត្វ
- ស្រាវជ្រាវ ចងក្រង បណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសស្តីពីការជ្រើសរើស និងការបង្កាត់ពូជសត្វ
- សម្របសម្រួលការអនុវត្តគម្រោងសហប្រតិបត្តិការជាមួយបណ្តាដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ និងវិស័យឯកជន ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ និងគ្រប់គ្រងសេនេទិកសត្វ
- រៀបចំរបាយការណ៍សកម្មភាពការងារជូននាយកដ្ឋាន តាមគោលការណ៍កំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

**៣.៤-ការិយាល័យគ្រប់គ្រងកាកសំណល់សត្វ ៖**

- ចូលរួមរៀបចំផែនការអភិវឌ្ឍន៍ និងលិខិតបទដ្ឋានពាក់ព័ន្ធការគ្រប់គ្រងកាកសំណល់សត្វ
- រៀបចំផែនការ សកម្មភាព គម្រោងថវិកា ទាក់ទងការងារគ្រប់គ្រងកាកសំណល់សត្វ
- ស្រាវជ្រាវ រៀបចំចងក្រងឯកសារបច្ចេកទេស និងបទពិសោធន៍ថ្មីៗទាក់ទងការងារគ្រប់គ្រងកាកសំណល់សត្វ និងផលប៉ះពាល់បរិស្ថាន

- ប្រមូល វិភាគ ចងក្រងទិន្នន័យ ស្រង់ស្ថិតិឡជីវឧស្ម័ន
- គ្រប់គ្រងកាកសំណល់សត្វ គ្រប់គ្រងការងារឡជីវឧស្ម័ន តាមដាន និងវាយតម្លៃផលប៉ះពាល់បរិស្ថាន
- ស្រាវជ្រាវ ប្រមូល រៀបចំចងក្រង បោះពុម្ពឯកសារបច្ចេកទេស និងប្រសិទ្ធភាពសេដ្ឋកិច្ចទាក់ទងការគ្រប់គ្រងកាកសំណល់សត្វ និងឡជីវឧស្ម័ន
- បណ្តុះបណ្តាលស្តីពីការគ្រប់គ្រងកាកសំណល់សត្វ បច្ចេកទេសឡជីវឧស្ម័នដល់អ្នកចិញ្ចឹមសត្វ និងអ្នកពាក់ព័ន្ធ
- ណែនាំ ផ្តល់សេវា និងប្រឹក្សាយោបល់លើការគ្រប់គ្រងកាកសំណល់សត្វ និងឡជីវឧស្ម័នដល់អ្នកចិញ្ចឹមសត្វ និងអ្នកពាក់ព័ន្ធ
- រៀបចំបទដ្ឋានបច្ចេកទេសស្តីពីឡជីវឧស្ម័ន
- សម្របសម្រួលការអនុវត្តគម្រោងសហប្រតិបត្តិការជាមួយបណ្តាដៃគូអភិវឌ្ឍន៍នានា ដើម្បីកៀរគរថវិកាគាំទ្រការអនុវត្តលើការគ្រប់គ្រងកាកសំណល់សត្វ និងឡជីវឧស្ម័ន
- វាយតម្លៃប្រសិទ្ធភាពសេដ្ឋកិច្ចលើការគ្រប់គ្រងកាកសំណល់សត្វ និងឡជីវឧស្ម័ន
- រៀបចំរបាយការណ៍សកម្មភាពការងារជូននាយកដ្ឋាន តាមគោលការណ៍កំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

៣.៥-ការិយាល័យគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ ៖

- ចូលរួមរៀបចំផែនការអភិវឌ្ឍន៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ
- រៀបចំផែនការ សកម្មភាព គម្រោងថវិកាទាក់ទងការងារគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ
- ស្រាវជ្រាវ រៀបចំចងក្រងឯកសារបច្ចេកទេស និងបទពិសោធន៍ថ្មីៗទាក់ទងការងារគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ
- ប្រមូល វិភាគ ចងក្រងទិន្នន័យ ជំរឿន ស្រង់ស្ថិតិទីកន្លែងចិញ្ចឹមសត្វ កសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងទិញលក់សត្វ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃទីកន្លែងចិញ្ចឹមសត្វ កសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងទិញលក់សត្វ និងការអនុវត្តស្តីពីសុខុមាលភាពសត្វ
- ត្រួតពិនិត្យ និងតាមដានការប្រើប្រាស់សារធាតុលាយផ្សំចំណីនៅក្នុងទីកន្លែងចិញ្ចឹមសត្វ និងកសិដ្ឋានចិញ្ចឹមសត្វស្របតាមបមាណីយ
- ត្រួតពិនិត្យ ណែនាំការគ្រប់គ្រងកាកសំណល់នៅទីកន្លែងចិញ្ចឹមសត្វ កសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងទិញលក់សត្វ
- ពិនិត្យ ផ្តល់យោបល់ក្នុងការចេញលិខិតអនុញ្ញាតបង្កើតទីកន្លែងចិញ្ចឹមសត្វ កសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងទិញលក់សត្វ
- រៀបចំពីធីសារសម្រាប់វាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបទដ្ឋានបច្ចេកទេស និងការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP)

- ពិនិត្យ និងវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វសម្រាប់ការផ្តល់វិញ្ញាបនបត្របញ្ជាក់ការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP)
- រៀបចំចុះបញ្ជីកសិដ្ឋានចិញ្ចឹមសត្វ
- ណែនាំ ផ្តល់សេវា និងប្រឹក្សាយោបល់លើការបង្កើត ការគ្រប់គ្រងទីកន្លែងចិញ្ចឹមសត្វ កសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងទិញលក់សត្វ
- រៀបចំចងក្រងឯកសារបច្ចេកទេសនិងបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធ ស្តីពីការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP)
- រៀបចំរបាយការណ៍សកម្មភាពការងារជូននាយកដ្ឋាន តាមគោលការណ៍កំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

៣.៦-ការិយាល័យអត្តសញ្ញាណកម្មសត្វ ៖

- ចូលរួមរៀបចំផែនការអភិវឌ្ឍន៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការងារអត្តសញ្ញាណកម្មសត្វ និងប្រព័ន្ធតាមដានប្រភពសត្វ
- រៀបចំផែនការ សកម្មភាព គម្រោងថវិកា ទាក់ទងការងារអត្តសញ្ញាណកម្មសត្វ និងប្រព័ន្ធតាមដានប្រភពសត្វ
- សហការរៀបចំបង្កើតប្រព័ន្ធតាមដានអេឡិចត្រូនិច (E-Traceability System) តាមដានប្រភពសត្វ
- រៀបចំកម្មវិធី និងអនុវត្តប្រព័ន្ធអត្តសញ្ញាណកម្មសត្វ
- បណ្តុះបណ្តាលដល់មន្ត្រីទទួលបន្ទុកផលិតកម្មនិងបសុព្យាបាល លើការងារធ្វើអត្តសញ្ញាណកម្មសត្វ និងប្រព័ន្ធតាមដានប្រភពសត្វ
- សហការអប់រំ ណែនាំដល់អ្នកពាក់ព័ន្ធស្តីពីអត្តសញ្ញាណកម្មសត្វ និងប្រព័ន្ធតាមដានប្រភពសត្វ
- ពិនិត្យ និងវាយតម្លៃចុះបញ្ជីអត្តសញ្ញាណកម្មសត្វសម្រាប់គោលបំណងធ្វើអាជីវកម្មផលិតកម្ម និងការបង្កាត់ពូជ
- សម្របសម្រួលការអនុវត្តគម្រោងសហប្រតិបត្តិការជាមួយបណ្តាដៃគូអភិវឌ្ឍន៍នានា និងវិស័យឯកជន ដើម្បីគាំទ្រដល់ការអនុវត្តប្រព័ន្ធអត្តសញ្ញាណកម្មសត្វ និងប្រព័ន្ធតាមដានប្រភពសត្វ
- រៀបចំរបាយការណ៍សកម្មភាពការងារជូននាយកដ្ឋានតាមគោលការណ៍កំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

**ប្រការ៤ ..**

នាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល មានការិយាល័យចំណុះចំនួន០៦ ដូចខាងក្រោម៖

១-ការិយាល័យត្រួតពិនិត្យអនាម័យបសុព្យាបាល

២-ការិយាល័យផលិតផលបសុព្យាបាល

៣-ការិយាល័យអង្កេត តាមដាន និងប្រយុទ្ធប្រឆាំងជំងឺសត្វ

៤-ការិយាល័យគ្រប់គ្រងមន្ទីរព្យាបាលសត្វ

៥-ការិយាល័យសត្តឃាតដ្ឋាន និងកែច្នៃ

៦-ការិយាល័យអង្កេត តាមដាន និងប្រយុទ្ធប្រឆាំងជំងឺស៊ូណូស។

ការិយាល័យនីមួយៗ មានតួនាទីភារកិច្ច ដូចខាងក្រោម៖

៤.១-ការិយាល័យត្រួតពិនិត្យអនាម័យបសុព្យាបាល ៖

- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាទាក់ទងការងារត្រួតពិនិត្យអនាម័យបសុព្យាបាល
- ប្រមូលរៀបចំលិខិតបទដ្ឋានគតិយុត្តដែលទាក់ទងនឹងការគ្រប់គ្រង ត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ
- រៀបចំ និងចងក្រងឯកសារបច្ចេកទេស និងសេចក្តីណែនាំស្តីពីវិធានអនាម័យសត្វស្រប តាមបទដ្ឋានអង្គការសុខភាពសត្វពិភពលោក (OIE)
- ស្រាវជ្រាវឯកសារ និងរៀបចំបទដ្ឋានគតិយុត្ត និងលក្ខខណ្ឌតម្រូវអនាម័យនៃការនាំចេញ ការនាំចូល ការនាំឆ្លងកាត់ ចរាចរក្នុងផ្ទៃប្រទេសនូវសត្វ និងផលិតផលសត្វ យោងតាមស្តង់ដារ នៃអង្គការសុខភាពសត្វពិភពលោក (OIE) អង្គការពាណិជ្ជកម្មពិភពលោក (WTO) កិច្ច-ព្រមព្រៀងពាក់ព័ន្ធនានា និងដោយអនុលោមតាមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
- តាមដានវាយតម្លៃលើការអនុវត្តវិធានអនាម័យបសុព្យាបាល
- រៀបចំលិខិតអនុញ្ញាតដឹកជញ្ជូន និងវិញ្ញាបនបត្របសុព្យាបាល សម្រាប់ការនាំចេញ ការនាំចូល ការនាំឆ្លងកាត់ ចរាចរក្នុងផ្ទៃប្រទេសនូវសត្វ ផលិតផលសត្វ
- ត្រួតពិនិត្យអនាម័យ និងគ្រប់គ្រងចលនាសត្វ និងផលិតផលសត្វ
- ត្រួតពិនិត្យអនាម័យមធ្យោបាយដឹកជញ្ជូន ឧបករណ៍ដាក់សត្វ សម្ភារវេចខ្ចប់ផលិតផលសត្វ និងនៅតាមកន្លែងចិញ្ចឹមសត្វ កសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងបង្កាត់ពូជសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ស្ថានីយ៍ចត្តាឡីស័កសត្វ និងផលិតផលសត្វ ទីកន្លែងកែច្នៃផលិតផលសត្វ ទីកន្លែងអាជីវកម្មសត្វ មន្ទីរព្យាបាលសត្វ ទីកន្លែងព្យាបាលសត្វ
- រៀបចំ និងជំរុញការអនុវត្តបទដ្ឋានសុខុមាលភាពសត្វ
- គ្រប់គ្រងស្ថានីយ៍ចត្តាឡីស័កសត្វ និងផលិតផលសត្វ លើបទដ្ឋានបច្ចេកទេស អនាម័យសត្វនិងអនុវត្តវិធានបសុព្យាបាល
- ធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពការងារការិយាល័យជូននាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

៤.២-ការិយាល័យផលិតផលបសុព្យាបាល ៖

- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាទាក់ទងការងារគ្រប់គ្រងផលិតផលបសុព្យាបាល
- ស្រាវជ្រាវឯកសារ និងរៀបចំបទដ្ឋានគតិយុត្ត និងលក្ខខណ្ឌតម្រូវបច្ចេកទេសនៃការនាំចេញ ការនាំចូល ការនាំឆ្លងកាត់ ចរាចរក្នុងផ្ទៃប្រទេសនូវផលិតផលបសុព្យាបាល យោងតាមស្តង់ដារនៃអង្គការសុខភាពសត្វពិភពលោក (OIE) អង្គការពាណិជ្ជកម្មពិភពលោក

(WTO) កិច្ចព្រមព្រៀងពាក់ព័ន្ធនានា និងដោយអនុលោមតាមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ

- គ្រប់គ្រង និងធ្វើស្ថិតិកន្លែងលក់បសុឱសថ និងបរិក្ខារបសុពេទ្យ
- ត្រួតពិនិត្យទីកន្លែងផលិត កែច្នៃ សន្និធិ បសុឱសថ និងបរិក្ខារបសុពេទ្យ
- ត្រួតពិនិត្យបញ្ជីបសុឱសថដែលច្បាប់អនុញ្ញាត ឬហាមឃាត់ និងបទដ្ឋានបច្ចេកទេសសម្រាប់ការទុកដាក់ ថែរក្សា និងតាំងលក់ចែកចាយ
- ត្រួតពិនិត្យតាមដានសកម្មភាព ប្រសិទ្ធភាពនៃការផលិត និងការប្រើប្រាស់បសុឱសថ រួមបញ្ចូលភាពស៊ាំបសុឱសថ
- គ្រប់គ្រងទិន្នន័យនៃការប្រើប្រាស់បសុឱសថ
- សម្របសម្រួលរៀបចំផ្តល់យោបល់លើសំណើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មផលិតផលបសុព្យាបាល
- ត្រួតពិនិត្យលក្ខខណ្ឌបច្ចេកទេស និងប្រសិទ្ធភាពនៃផលិតផលបសុព្យាបាល ដែលនឹងត្រូវស្នើសុំចុះបញ្ជិកា
- ធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពការងារការិយាល័យជូននាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

**៤.៣-ការិយាល័យអង្កេត តាមដាន និងប្រយុទ្ធប្រឆាំងជំងឺសត្វ ៖**

- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាទាក់ទងការប្រយុទ្ធប្រឆាំងជំងឺសត្វ
- ធ្វើផែនការយុទ្ធសាស្ត្រទប់ស្កាត់ និងកំចាត់ជំងឺឆ្លងសត្វរយៈពេលវែង មធ្យម និងខ្លីស្របតាមផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ តំបន់ និងសកល
- ស្រាវជ្រាវឯកសារស្តីពីហានិភ័យ និងការកំណត់តំបន់ឆ្លងរាលដាលជំងឺសត្វតាមបទដ្ឋានអង្គការសុខភាពសត្វពិភពលោក (OIE) និងតំបន់
- សហការ សិក្សាស្រាវជ្រាវ អង្កេតតាមដានហានិភ័យនៃជំងឺឆ្លងសត្វ និងជំងឺវិញ្ញត្តិ
- ពិនិត្យ តាមដាន រាយការណ៍ជាប្រចាំ និងព័ត៌មានវិភាគជំងឺឆ្លងសត្វ ជំងឺវិញ្ញត្តិ និងកំណត់តំបន់ផ្ទុះជំងឺ និងតំបន់រណប
- អនុវត្តវិធានការបសុព្យាបាលក្នុងតំបន់ផ្ទុះជំងឺឆ្លងសត្វ ជំងឺវិញ្ញត្តិ និងក្នុងតំបន់រណប
- ពិនិត្យ វាយតម្លៃ ស្ថានភាពរាតត្បាតជំងឺឆ្លង និងធ្វើសំណើប្រកាសរំសាយ តំបន់ផ្ទុះជំងឺឆ្លងសត្វ ក្រោយពីបានសិក្សាលើហានិភ័យអំពីការឆ្លងជំងឺសត្វតាមបទដ្ឋានអង្គការសុខភាពសត្វពិភពលោក (OIE)
- ស្រាវជ្រាវរៀបចំឯកសារ និងបទពិសោធន៍ល្អៗទាក់ទងការងារសុខភាពសត្វ សម្រាប់បណ្តុះបណ្តាល
- ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីបណ្តុះបណ្តាលរបស់គ្រូបង្គោល និងភ្នាក់ងារសុខភាពសត្វភូមិនៅគ្រប់រាជធានី ខេត្ត

- ចូលរួមគ្រប់វេទិកាជាតិ និងអន្តរជាតិលើការអង្កេត តាមដាន ស្រាវជ្រាវ ការចែករំលែកព័ត៌មានស្តីពីការបង្ការ ទប់ស្កាត់ និងចាត់វិធានការប្រយុទ្ធប្រឆាំងជំងឺសត្វ និងជំងឺវិញត្តិ
- ជំរុញការអប់រំផ្សព្វផ្សាយអំពីសារៈប្រយោជន៍នៃវិធានការការពារជំងឺឆ្លងសត្វ
- វិភាគតាមដានស្ថានភាពជំងឺសត្វ និងស្នើវិធានការបសុព្យាបាល
- ធ្វើរបាយការណ៍អំពីប្រវត្តិពាក់ព័ន្ធជំងឺសត្វ និងធ្វើការសន្និដ្ឋានលើរោគវិនិច្ឆ័យគ្លីនិក
- តាមដាន និងរាយការណ៍ស្ថានភាពជំងឺសត្វនៅតាមបណ្តារាជធានី-ខេត្ត
- ជំរុញការអនុវត្តយុទ្ធនាការចាក់ថ្នាំការពារជំងឺឆ្លងសត្វ
- រលើកវិធានការ និងត្រៀមរៀបចំទុកជាមុននូវរាល់មធ្យោបាយ (ធនធានមនុស្ស សម្ភារ និងថវិកា) ក្នុងការឆ្លើយតបបន្ទាន់ទៅលើការផ្ទុះជំងឺឆ្លងសត្វ
- ចងក្រងឯកសារបច្ចេកទេស និងសេចក្តីណែនាំលើវិធានការការពារ ព្យាបាល និងផលប៉ះពាល់នៃជំងឺឆ្លងសត្វ
- ធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពការងារការិយាល័យជូននាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

**៤.៤-ការិយាល័យគ្រប់គ្រងមន្ទីរព្យាបាលសត្វ ៖**

- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាទាក់ទងការងារគ្រប់គ្រងមន្ទីរព្យាបាលសត្វ និងកន្លែងរក្សាសត្វ
- ចងក្រងឯកសារបច្ចេកទេសសម្រាប់បណ្តុះបណ្តាល និងសេចក្តីណែនាំស្តីពីការព្យាបាល ត្រួតពិនិត្យជំងឺសត្វ
- សម្របសម្រួលការប្រព្រឹត្តទៅរបស់គណៈបសុពេទ្យ
- រៀបចំស្តង់ដារ និងចំណាត់ថ្នាក់នៃសេវាកម្មពិនិត្យព្យាបាលសត្វ និងកន្លែងរក្សាសត្វ
- ពិនិត្យផ្តល់យោបល់ក្នុងការអនុញ្ញាតឲ្យបង្កើតទីកន្លែងព្យាបាលសត្វ និងមន្ទីរពិនិត្យព្យាបាលសត្វ
- ចែករំលែកព័ត៌មានស្តីពីស្ថានភាពជំងឺសត្វតូច និងវិធានបសុព្យាបាល
- ត្រួតពិនិត្យ និងផ្តល់សេវាកម្មក្នុងការអនុវត្តវិធានការបសុព្យាបាល
- ធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពការងារការិយាល័យជូនថ្នាក់ដឹកនាំនាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

**៤.៥-ការិយាល័យសត្តឃាតដ្ឋាន និងកែច្នៃ ៖**

- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាទាក់ទងការងារសត្តឃាតដ្ឋាន និងការកែច្នៃបឋមផលិតផលសត្វ
- ពិនិត្យ វាយតម្លៃ និងធ្វើរបាយការណ៍បច្ចេកទេសក្នុងការបង្កើតសត្តឃាតដ្ឋាន និងក្នុងការបង្កើតកន្លែងកែច្នៃបឋមផលិតផលសត្វ
- បណ្តុះបណ្តាលបច្ចេកទេស អនាម័យសាច់ដល់អាជីវករពិឃាតសត្វ និងមន្ត្រីជំនាញ
- គ្រប់គ្រងស្ថិតិសត្តឃាតដ្ឋាន អាជីវកម្មពិឃាតសត្វ និងកន្លែងកែច្នៃបឋមផលិតផលសត្វ

- ត្រួតពិនិត្យអនាម័យសាច់ និងបទដ្ឋានបច្ចេកទេសសត្តឃាតដ្ឋាន និងកន្លែងកែច្នៃបឋមផលិតផលសត្វ
- ត្រួតពិនិត្យអនាម័យលើមធ្យោបាយដឹកជញ្ជូនសាច់ និងផលិតផលសត្វ
- ត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វ នៅសត្តឃាតដ្ឋាន កន្លែងកែច្នៃបឋមផលិតផលសត្វ និងកន្លែងតាំងលក់
- ត្រួតពិនិត្យសត្វ មុន និងក្រោយពេលពិឃាត
- ធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពការងារការិយាល័យជូនថ្នាក់ដឹកនាំនាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

៤.៦-ការិយាល័យអង្កេត តាមដាន និងប្រយុទ្ធប្រឆាំងជំងឺស៊ុយណូស ៖

- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាទាក់ទងការងារប្រឆាំងជំងឺស៊ុយណូស
- ធ្វើផែនការយុទ្ធសាស្រ្តទប់ស្កាត់ និងកំចាត់ជំងឺស៊ុយណូសរយៈពេលវែង មធ្យមនិងខ្លីស្របតាមផែនការយុទ្ធសាស្រ្តថ្នាក់ជាតិ តំបន់ និងសកល
- ចងក្រងឯកសារលិខិតបទដ្ឋានគតិយុត្ត និងរៀបចំប្រព័ន្ធព័ត៌មានស្តីពីជំងឺឆ្លងពីសត្វមកមនុស្ស ពីមនុស្សមកសត្វ និងជំងឺដែលបណ្តាលមកពីម្ហូបអាហារ
- ស្រាវជ្រាវឯកសារស្តីពីហានិភ័យ និងការកំណត់តំបន់ឆ្លងរាលដាលជំងឺស៊ុយណូស តាមបទដ្ឋានអង្គការសុខភាពសត្វពិភពលោក (OIE) និងតំបន់
- សហការ សិក្សាស្រាវជ្រាវ អង្កេតតាមដានហានិភ័យនៃជំងឺស៊ុយណូស
- ពិនិត្យ តាមដាន រាយការណ៍ជាប្រចាំ និងព័ត៌មានវិភាគជំងឺស៊ុយណូស និងកំណត់តំបន់ផ្ទុះជំងឺ និងតំបន់រណប
- អនុវត្តន៍វិធានការបសុព្យាបាលក្នុងតំបន់ផ្ទុះជំងឺស៊ុយណូស និងក្នុងតំបន់រណប
- ពិនិត្យ វាយតម្លៃ ស្ថានភាពរាតត្បាតជំងឺស៊ុយណូស និងធ្វើសំណើប្រកាសរំសាយ តំបន់ផ្ទុះជំងឺស៊ុយណូស ក្រោយពីបានសិក្សាលើហានីភ័យអំពីការឆ្លង ជំងឺស៊ុយណូសតាមបទដ្ឋានអង្គ-ការសុខភាពសត្វពិភពលោក (OIE)
- ចូលរួមគ្រប់វេទិកាជាតិ និងអន្តរជាតិលើការអង្កេត តាមដាន ស្រាវជ្រាវ ការចែករំលែកព័ត៌មានស្តីពីការបង្ការ ទប់ស្កាត់ និងចាត់វិធានការប្រយុទ្ធប្រឆាំងជំងឺស៊ុយណូស
- ត្រួតពិនិត្យ និងធ្វើរោគវិនិច្ឆ័យបឋមជំងឺស៊ុយណូស លើសាច់ និងផលិតផលសត្វ នៅតាមសត្តឃាតដ្ឋាន កន្លែងកែច្នៃបឋមផលិតសត្វ និងកន្លែងតាំងលក់លើទីផ្សារ
- ចូលរួមផ្តល់យោបល់លើការងារសុខភាពសាធារណៈពាក់ព័ន្ធនឹងជំងឺឆ្លងពីសត្វមកមនុស្សពីមនុស្សមកសត្វ និងជំងឺដែលបណ្តាលមកពីម្ហូបអាហារ
- ធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពការងារការិយាល័យជូនថ្នាក់ដឹកនាំនាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

ប្រការ៥ ..

នាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម មានការិយាល័យចំណុះចំនួន០៥ ដូចខាងក្រោម៖

១-ការិយាល័យផ្សព្វផ្សាយបច្ចេកទេស

២-ការិយាល័យអភិវឌ្ឍន៍សហគមន៍

៣-ការិយាល័យនីតិកម្ម និងដោះស្រាយវិវាទ

៤-ការិយាល័យចុះបញ្ជីចំណីសត្វ និងបសុឱសថ

៥-ការិយាល័យស្រាវជ្រាវ និងអធិការកិច្ច។

ការិយាល័យនីមួយៗ មានតួនាទីភារកិច្ច ដូចខាងក្រោម៖

៥.១-ការិយាល័យផ្សព្វផ្សាយបច្ចេកទេស ៖

- ចូលរួមរៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាទាក់ទងលើការងារចងក្រងឯកសារ និងបោះពុម្ព អប់រំបណ្តុះបណ្តាលផ្សព្វផ្សាយបច្ចេកទេសសុខភាពសត្វ និងផលិតកម្មសត្វ
- រៀបចំ គ្រប់គ្រង និងចាត់ចែងលិខិតស្នាមរដ្ឋបាល ចេញ-ចូល ឯកសារនានា ដែលពាក់ព័ន្ធការងាររបស់ការិយាល័យ
- សហការសម្របសម្រួលការអនុវត្តគម្រោងសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ ផ្នែកឯកជន និងដៃគូអភិវឌ្ឍនានា
- បណ្តុះបណ្តាលវិធីសាស្ត្រផ្សព្វផ្សាយដល់មន្ត្រីបច្ចេកទេស និងអ្នកពាក់ព័ន្ធលើការងារសុខភាពសត្វ និងផលិតកម្មសត្វ
- សិក្សាស្រាវជ្រាវ រៀបចំបទដ្ឋានគតិយុត្ត និងបមាណីយនានាក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ
- សហការវិភាគផ្សព្វផ្សាយព័ត៌មានទីផ្សារ តម្រូវការ ការផ្គត់ផ្គង់ និងតម្លៃសត្វ ផលិតផលសត្វ បសុឱសថ ចំណីសត្វ និងវត្ថុធាតុដើមសម្រាប់លាយផ្សំចំណី
- សហការផ្សព្វផ្សាយបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យសុខភាពសត្វ និងផលិតកម្មសត្វតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ និងឯកជន
- ចូលរួមផ្តល់ឯកសារបច្ចេកទេស និងព័ត៌មានសកម្មភាពសុខភាពសត្វ និងផលិតកម្មសត្វទៅអ្នកពាក់ព័ន្ធ និងស្ថាប័ននានា
- គ្រប់គ្រង ត្រួតពិនិត្យ តាមដាន វាយតម្លៃការផ្សព្វផ្សាយលើវិស័យសុខភាពសត្វ និងផលិតកម្មសត្វ និងសហការអនុវត្តបង្ហាញ
- រៀបចំ ចងក្រង កែសម្រួល និងបោះពុម្ពឯកសារបច្ចេកទេសស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ មានដូចជា៖ ព្រឹត្តបត្រ ទស្សនាវដ្តី ឯកសារបច្ចេកទេស ផ្ទាំងរូបភាព ផលិត (Spot) និងសម្ភារផ្សេងៗសម្រាប់អប់រំ ផ្សព្វផ្សាយ
- រៀបចំ និងគ្រប់គ្រងគេហទំព័រវេងផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម
- ស្រាវជ្រាវ ប្រមូលផ្តុំចងក្រងទិន្នន័យ ឯកសារ អត្ថបទបច្ចេកទេស ច្បាប់ បទដ្ឋានគតិយុត្ត ព័ត៌មានផ្សេងៗ និងរក្សាទុកដាក់ឯកសារ

- សហការប្រមូលព័ត៌មានលើការងារផ្សព្វផ្សាយជាមួយអង្គភាពចំណុះអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត ក្រុមហ៊ុន អង្គការជាតិ និងអន្តរជាតិ ពាក់ព័ន្ធវិស័យសុខភាពសត្វ និងផលិតកម្មសត្វ
- រៀបចំរបាយការណ៍ប្រចាំខែ និងលើកទិសដៅការងារជូនថ្នាក់ដឹកនាំនាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

៥.២-ការិយាល័យអភិវឌ្ឍន៍សហគមន៍ ៖

- ចូលរួមរៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាទាក់ទងលើការងារអភិវឌ្ឍន៍សហគមន៍
- រៀបចំ គ្រប់គ្រង និងចាត់ចែងលិខិតស្នាមរដ្ឋបាល ចេញ-ចូល ឯកសារនានា ដែលពាក់ព័ន្ធការងាររបស់ការិយាល័យ
- សហការសម្របសម្រួលការអនុវត្តគម្រោងសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ ផ្នែកឯកជន និងដៃគូអភិវឌ្ឍនានា
- សិក្សា និងរៀបចំគោលនយោបាយក្របខណ្ឌគតិយុត្ត និងផែនការយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍន៍សហគមន៍
- ចងក្រង រៀបចំបង្កើត តាមដានត្រួតពិនិត្យវាយតម្លៃសហគមន៍ចិញ្ចឹមសត្វ សហគមន៍ភ្នាក់ងារសុខភាពសត្វភូមិ សហគមន៍ និងអង្គការនានាដែលពាក់ព័ន្ធការងារសុខភាពសត្វ និងផលិតកម្មសត្វ
- រៀបចំ និងអភិវឌ្ឍធនធានមនុស្សឱ្យមានសមត្ថភាពដើម្បីគ្រប់គ្រង និងចាត់ចែងការងារបង្កើតសហគមន៍
- ជំរុញ គាំទ្រ និងធានាចំពោះការប្រព្រឹត្តិទៅ និងការអភិវឌ្ឍន៍សហគមន៍
- ចុះបញ្ជី និងការគ្រប់គ្រងបញ្ជីការរបស់សហគមន៍ដែលបានបង្កើតឡើង
- សិក្សា និងរៀបចំប្រព័ន្ធគណនេយ្យសម្រាប់ការចុះបញ្ជី និងការជម្រះបញ្ជីរបស់សហគមន៍
- អនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំ និងផ្តល់សេវាកម្មបណ្តុះបណ្តាលដល់សមគមន៍
- ប្រមូលឯកសារបច្ចេកទេស និងបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងសហគមន៍ដើម្បីតម្កល់ទុកសម្រាប់ការស្រាវជ្រាវ និងការអប់រំបណ្តុះបណ្តាល
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍសហគមន៍
- សម្របសម្រួលរវាងសហគមន៍ជាមួយវិស័យឯកជន ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងប្រទេស និងក្រៅប្រទេសដើម្បីធានាប្រសិទ្ធភាព ចំពោះដំណើរការអភិវឌ្ឍសហគមន៍
- សម្របសម្រួល និងចូលរួមដោះស្រាយវិវាទ ដែលកើតឡើងក្នុងដំណើរការអភិវឌ្ឍសហគមន៍
- សិក្សា និងវិភាគស្ថានភាពរបស់សហគមន៍ ដើម្បីឆ្លើយតបទៅនឹងដំណើរការទីផ្សារ
- ផ្តល់យោបល់ និងឈានទៅលុបឈ្មោះសហគមន៍ពេលដែលរំសាយ ឬអសកម្ម
- ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំស្តីពីដំណើរការសហគមន៍ជូនថ្នាក់ដឹកនាំនាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

៥.៣-ការិយាល័យនីតិកម្ម និងដោះស្រាយវិវាទ ៖

- ចូលរួមរៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាទាក់ទងលើការងារនីតិកម្ម និងដោះស្រាយវិវាទ
- រៀបចំ គ្រប់គ្រង និងចាត់ចែងលិខិតស្នាមរដ្ឋបាល ចេញ-ចូល ឯកសារនានា ដែលពាក់ព័ន្ធការងាររបស់ការិយាល័យ
- ពិនិត្យ សិក្សា តម្រូវការច្បាប់លិខិតបទដ្ឋានគតិយុត្តទាក់ទងការគ្រប់គ្រងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ និងលើកសំណើ
- ទទួលសំណុំរឿង និងកសាងសំណុំរឿង ពិនិត្យផ្ដល់យោបល់លើនីតិវិធីដោះស្រាយរឿងក្ដីឬវិវាទជូននាយកដ្ឋាន
- ចូលរួមក្នុងការងារអនុវត្តសាលក្រម ឬសាលដីកានានាពាក់ព័ន្ធ
- ពិនិត្យ តាមដាន និងវាយតម្លៃក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- សិក្សាស្រាវជ្រាវ រៀបចំបទដ្ឋានគតិយុត្ត បមាណីយនិងលក្ខខណ្ឌតម្រូវនានាក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ
- រៀបចំរបាយការណ៍ប្រចាំខែ និងលើកទិសដៅការងារជូនថ្នាក់ដឹកនាំនាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

៥.៤-ការិយាល័យចុះបញ្ជីចំណីសត្វ និងបសុឱសថ ៖

- ចូលរួមរៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាទាក់ទងលើការងារចុះបញ្ជីចំណីសត្វ និងបសុឱសថ
- រៀបចំ គ្រប់គ្រង និងចាត់ចែងលិខិតស្នាមរដ្ឋបាល ចេញ-ចូល ឯកសារនានា ដែលពាក់ព័ន្ធការងាររបស់ការិយាល័យ
- សហការសម្របសម្រួលការអនុវត្តគម្រោងសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ ផ្នែកឯកជន និងដៃគូអភិវឌ្ឍនានា
- សិក្សាស្រាវជ្រាវ រៀបចំ លិខិតបទដ្ឋានគតិយុត្ត និងលក្ខខណ្ឌតម្រូវនានាពាក់ព័ន្ធបសុឱសថ និងចំណីសត្វ
- រៀបចំឯកសារពាក់ព័ន្ធនានាក្នុងការចុះបញ្ជិកាបសុឱសថ និងចំណីសត្វ
- ពិនិត្យផ្ដល់យោបល់ វាយតម្លៃលើការចុះបញ្ជីបសុឱសថ និងចំណីសត្វ
- រៀបចំរបាយការណ៍ប្រចាំខែ និងលើកទិសដៅការងារជូនថ្នាក់ដឹកនាំនាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

៥.៥-ការិយាល័យស្រាវជ្រាវ និងអធិការកិច្ច ៖

- ចូលរួមរៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាទាក់ទងលើការងារស្រាវជ្រាវ និងអធិការកិច្ច
- រៀបចំ គ្រប់គ្រង និងចាត់ចែងលិខិតស្នាមរដ្ឋបាល ចេញ-ចូល ឯកសារនានា ដែលពាក់ព័ន្ធការងាររបស់ការិយាល័យ

- តាមដានការអនុវត្តច្បាប់ និងធ្វើអធិការកិច្ច
- ធ្វើអន្តរាគមន៍ និងចុះជួយទប់ស្កាត់បទល្មើសទាក់ទងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ
- ធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មពាក់ព័ន្ធលើវិស័យសុខភាពសត្វ និងផលិតកម្មសត្វ
- ពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចនៅក្នុងការអនុវត្តច្បាប់ និងដោះស្រាយវិវាទ
- រៀបចំរបាយការណ៍ប្រចាំខែ និងលើកទិសដៅការងារជូនថ្នាក់ដឹកនាំនាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

**ប្រការ៦ .-**

វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វនិងផលិតកម្មសត្វ មានការិយាល័យចំណុះចំនួន០១ និងអង្គភាពចំណុះចំនួន០៩ ដូចខាងក្រោម៖

១-ការិយាល័យអេពីដេមីសាស្ត្រ និងវិភាគព័ត៌មាន
២-មន្ទីរពិសោធន៍សេនេទិកពូជសត្វ
៣-មន្ទីរពិសោធន៍បសុឱសថ និងកាកសំណល់បសុឱសថ
៤-មន្ទីរពិសោធន៍គុណភាពចំណីសត្វ
៥-មន្ទីរពិសោធន៍វីរុសសាស្ត្រ
៦-មន្ទីរពិសោធន៍បាក់តេរីសាស្ត្រ និងមីកូសាស្ត្រ
៧-មន្ទីរពិសោធន៍ប៉ារ៉ាសិតសាស្ត្រ
៨-មន្ទីរពិសោធន៍រោគសាស្ត្រ
៩-មន្ទីរពិសោធន៍ជីវគីមី និងវិសសាស្ត្រ (Toxicology)
១០-ស្ថានីយស្រាវជ្រាវផលិតកម្មនិងបសុព្យាបាល ។

មន្ទីរពិសោធន៍ និងស្ថានីយមានឋានានុក្រមស្មើការិយាល័យថ្នាក់កណ្តាល។

ការិយាល័យ និងអង្គភាពចំណុះនីមួយៗមានតួនាទីភារកិច្ចដូចខាងក្រោម ៖

**៦.១-ការិយាល័យអេពីដេមីសាស្ត្រ និងវិភាគព័ត៌មាន ៖**

- ចូលរួមរៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាសម្រាប់ការងារស្រាវជ្រាវជំងឺសត្វ
- អង្កេត តាមដាន ឃ្លាំមើល និងស្រាវជ្រាវជំងឺឆ្លងសត្វ
- តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីអង្កេត តាមដាន ឃ្លាំមើល និងស្រាវជ្រាវជំងឺឆ្លងសត្វ
- វាយតម្លៃប្រព័ន្ធអង្កេត តាមដាន និងឃ្លាំមើលជំងឺឆ្លងសត្វ
- សិក្សាអេពីដេមីសាស្ត្រ និងស្ថានភាពរាតត្បាតនៃជំងឺឆ្លងសត្វ
- សិក្សា វាយតម្លៃពីកត្តាហានិភ័យលើផលប៉ះពាល់ពាក់ព័ន្ធជំងឺឆ្លងសត្វ
- ស្រាវជ្រាវ និងកំណត់ប្រភពនៃការផ្ទុះជំងឺឆ្លងសត្វ
- ស្រាវជ្រាវ និងកំណត់មូលហេតុនៃភាពស៊ាំរបស់មេរោគទៅនឹងបសុឱសថ
- គ្រប់គ្រង និងថែរក្សាទុកស្តុកសេរ៉ូម
- គ្រប់គ្រង និងចងក្រងឯកសារ និងផ្សព្វផ្សាយ
- គ្រប់គ្រងទិន្នន័យសម្រាប់ការងារស្រាវជ្រាវរបស់វិទ្យាស្ថាន

- តាមដាន វាយតម្លៃការអនុវត្តផែនការស្រាវជ្រាវរបស់វិទ្យាស្ថាន
- គ្រប់គ្រង និងចាត់ចែងសេវារដ្ឋបាល ការងារបុគ្គលិកក្នុងវិទ្យាស្ថាន
- គ្រប់គ្រងបញ្ជីគណនេយ្យ និងថវិកាសម្រាប់ដំណើរការរបស់វិទ្យាស្ថាន
- វិភាគព័ត៌មាន និងវាយតម្លៃស្ថានភាពអេពីដេមីសាស្ត្រ និងរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- គ្រប់គ្រង រៀបចំ ចងក្រង និងតម្កល់ឯកសារលទ្ធផលស្រាវជ្រាវសុខភាពសត្វ ជំងឺឆ្លងសត្វ
- រៀបចំឯកសារ និងបណ្ដុះបណ្ដាលអេពីដេមីសាស្ត្រ
- បូកសរុបរបាយការណ៍លទ្ធផលការងារស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ជូន។

៦.២-មន្ទីរពិសោធន៍សេនេទិកពូជសត្វ ៖

- ចូលរួមរៀបចំផែនការ កម្មវិធី សកម្មភាព និងគម្រោងថវិកាការងារស្រាវជ្រាវសេនេទិកពូជសត្វ
- សិក្សា ពិសោធ ស្រាវជ្រាវសេនេទិកពូជសត្វ និងការបង្កាត់ពូជសត្វនៅទីពិសោធន៍
- សិក្សាលក្ខណៈសម្បត្តិនៃពូជសត្វ ភាពធន់ និងបន្សាំទៅនឹងមជ្ឈដ្ឋានជុំវិញក្នុងតំបន់
- ធ្វើការសិក្សាវាយតម្លៃជីវចម្រុះ ស្រាវជ្រាវ និងប្រើប្រាស់ធនធានសេនេទិកពូជសត្វប្រកបដោយនិរន្តរភាព
- សិក្សា និងកំណត់ស្តង់ដារប្រព័ន្ធផលិតកម្មសត្វ
- សិក្សា ស្រាវជ្រាវអំពីជីវៈបច្ចេកវិជ្ជា ម៉ូលេគុល ដើម្បីកែលម្អប្រព័ន្ធផលិតកម្មសត្វ
- សិក្សា ស្រាវជ្រាវលើការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងសេនេទិកពូជសត្វ
- អភិវឌ្ឍបច្ចេកទេសសមស្របសម្រាប់វាយតម្លៃពូជសត្វ និងការបង្កាត់ពូជសត្វ
- សិក្សាលើកត្តាផ្សេងៗដែលជះឥទ្ធិពលលើការបន្តពូជ និងការលូតលាស់របស់សត្វ
- អនុវត្តកម្មវិធីវិភាគ ព្យាសកម្ម (calibration) និងប្រៀបធៀបលទ្ធផលជាមួយមន្ទីរពិសោធន៍យោង (Reference Lab) ជាតិ តំបន់ និងអន្តរជាតិ
- រៀបចំមន្ទីរពិសោធន៍ស្របតាមស្តង់ដារ ISO មន្ទីរពិសោធន៍
- រៀបចំ ចងក្រងបមាណីយនីតិវិធីប្រតិបត្តិ (SOP) សម្រាប់ការធ្វើវិភាគ និងធ្វើបច្ចុប្បន្នភាពតាមការវិវឌ្ឍន៍នៃការវិភាគ និងផលិត
- រៀបចំ ចងក្រងឯកសារ និងបណ្ដុះបណ្ដាលការងារស្រាវជ្រាវសេនេទិកពូជសត្វ និងការបង្កាត់ពូជសត្វ
- ត្រួតពិនិត្យ និងវាយតម្លៃដំណើរការរបស់មន្ទីរពិសោធន៍ស្រាវជ្រាវសេនេទិកពូជសត្វ
- ផ្តល់សេវាកម្មស្រាវជ្រាវសេនេទិកពូជសត្វ និងការបង្កាត់ពូជសត្វ
- សហការជាមួយមន្ទីរពិសោធន៍នានា អង្គការជាតិ អង្គការអន្តរជាតិ អង្គភាព និងស្ថាប័នពាក់ព័ន្ធការងារស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ

- សម្របសម្រួល ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់សម្រាប់ការអនុញ្ញាតលើសំណើសុំ បង្កើតមន្ទីរពិសោធន៍សុខភាពសត្វ និងផលិតកម្មសត្វ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ជូន។

៦.៣-មន្ទីរពិសោធន៍បសុឱសថ និងកាកសំណល់បសុឱសថ ៖

- ចូលរួមរៀបចំផែនការ កម្មវិធី សកម្មភាពគម្រោងថវិកាការងារស្រាវជ្រាវបសុឱសថ និងកាកសំណល់បសុឱសថនៅក្នុងសត្វ និងផលិតផលសត្វ
- វិភាគ ពិសោធន៍ ស្រាវជ្រាវគុណភាព និងផលិតបសុឱសថ និងថ្នាំការពារជំងឺសត្វ
- វិភាគរកកាកសំណល់បសុឱសថក្នុងសត្វ និងផលិតផលសត្វ
- ស្រាវជ្រាវ ពិសោធន៍ប្រសិទ្ធភាពបសុឱសថ
- អនុវត្តកម្មវិធីវិភាគ ព្យាសកម្ម (calibration) និងប្រៀបធៀបលទ្ធផលជាមួយមន្ទីរពិសោធន៍យោង (Reference Lab) ជាតិ តំបន់ និងអន្តរជាតិ
- រៀបចំមន្ទីរពិសោធន៍ស្របតាមស្តង់ដារ ISO មន្ទីរពិសោធន៍
- រៀបចំ ចងក្រងបមាណីយនីតិវិធីប្រតិបត្តិ (SOP) សម្រាប់ការធ្វើវិភាគ និងធ្វើបច្ចុប្បន្នភាពតាមការវិវឌ្ឍនៃការវិភាគ និងផលិត
- រៀបចំ ចងក្រងឯកសារ និងបណ្តុះបណ្តាលវិធីសាស្ត្រធ្វើវិភាគ និងផលិត និងការយកវត្ថុវិភាគ
- ត្រួតពិនិត្យ និងវាយតម្លៃដំណើរការរបស់មន្ទីរពិសោធន៍បសុឱសថ និងកាកសំណល់បសុឱសថ
- សហការជាមួយមន្ទីរពិសោធន៍នានា អង្គការជាតិ អង្គការអន្តរជាតិ អង្គភាព និងស្ថាប័នពាក់ព័ន្ធការងារស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ
- ផ្តល់សេវាកម្មវិភាគបសុឱសថ និងកាកសំណល់បសុឱសថក្នុងសត្វ និងផលិតផលសត្វ
- សម្របសម្រួល ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់សម្រាប់ការអនុញ្ញាតលើសំណើសុំ បង្កើតមន្ទីរពិសោធន៍សុខភាពសត្វ និងផលិតកម្មសត្វ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ជូន។

៦.៤-មន្ទីរពិសោធន៍គុណភាពចំណីសត្វ ៖

- ចូលរួមរៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាការងារស្រាវជ្រាវគុណភាពចំណីសត្វ
- សិក្សា ពិសោធ ស្រាវជ្រាវការងារចិញ្ចឹមសត្វ ចំណីសត្វ និងការផ្តល់ចំណីសត្វ
- សិក្សា ពិសោធ ស្រាវជ្រាវប្រសិទ្ធភាពសេដ្ឋកិច្ច និងប្រសិទ្ធភាពនៃចំណីសត្វ
- សិក្សា ពិសោធ ស្រាវជ្រាវ ចំណីសត្វ សារធាតុផ្សំ សារធាតុបន្ថែមផ្សេងៗទៀតសម្រាប់ចំណីសត្វ ដើម្បីកំណត់បមាណីយចំណីសត្វ
- វិភាគ ពិសោធ និងស្រាវជ្រាវលើគុណភាព និងសុវត្ថិភាពចំណីសត្វ សារធាតុចិញ្ចឹម សារធាតុផ្សំចំណីសត្វ សារធាតុបន្ថែមផ្សេងទៀត
- អនុវត្តកម្មវិធីវិភាគ ព្យាសកម្ម (calibration) និងប្រៀបធៀបលទ្ធផលជាមួយមន្ទីរពិសោធន៍យោង (Reference Lab) ជាតិ តំបន់ និងអន្តរជាតិ

- រៀបចំមន្ទីរពិសោធន៍ស្របតាមស្តង់ដារ ISO មន្ទីរពិសោធន៍
- រៀបចំ ចងក្រងបមាណីយនីតិវិធីប្រតិបត្តិ (SOP) សម្រាប់ការវិភាគចំណីសត្វ និងធ្វើបច្ចុប្បន្នភាពតាមការវិវឌ្ឍន៍នៃតេស្ត
- រៀបចំឯកសារ និងបណ្តុះបណ្តាលបច្ចេកទេសវិភាគគុណភាពចំណីសត្វ ការប្រើប្រាស់ចំណីសត្វ និងវិធីសាស្ត្រយកវត្ថុវិភាគ
- ត្រួតពិនិត្យ និងវាយតម្លៃដំណើរការរបស់មន្ទីរពិសោធន៍វិភាគចំណីសត្វ
- ផ្តល់សេវាកម្មវិភាគចំណីសត្វ វត្ថុធាតុដើមផ្សំចំណីសត្វ សមាសធាតុផ្សំ និងសារធាតុបន្ថែមផ្សេងទៀតសម្រាប់ចំណីសត្វ
- សហការជាមួយមន្ទីរពិសោធន៍នានា អង្គការជាតិ អង្គការអន្តរជាតិ អង្គភាព និងស្ថាប័នពាក់ព័ន្ធការងារស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ
- សម្របសម្រួល ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់សម្រាប់ការអនុញ្ញាតលើសំណើសុំបង្កើតមន្ទីរពិសោធន៍សុខភាពសត្វ និងផលិតកម្មសត្វ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ជូន។

៦.៥-មន្ទីរពិសោធន៍វីរុសសាស្ត្រ ៖

- ចូលរួមរៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាការងារធ្វើរោគវិនិច្ឆ័យជំងឺបង្កដោយវីរុស និងភាពស៊ាំរបស់សត្វទៅនឹងវីរុស
- ធ្វើរោគវិនិច្ឆ័យជំងឺបង្កដោយវីរុស និងកំណត់ប្រភេទវីរុសដែលបង្កជំងឺលើសត្វ
- សិក្សា ពិសោធ ស្រាវជ្រាវការវិវត្តន៍របស់វីរុស
- សិក្សា ពិសោធ ស្រាវជ្រាវភាពស៊ាំរបស់សត្វទៅនឹងជំងឺបង្កដោយវីរុស
- អនុវត្តកម្មវិធីវិភាគ ព្យាសកម្ម(calibration)និងប្រៀបធៀបលទ្ធផលជាមួយមន្ទីរពិសោធន៍យោង (Reference Lab) ជាតិ តំបន់ និងអន្តរជាតិ
- រៀបចំមន្ទីរពិសោធន៍ស្របតាមស្តង់ដារ ISO មន្ទីរពិសោធន៍
- រៀបចំ ចងក្រងបមាណីយនីតិវិធីប្រតិបត្តិ (SOP) សម្រាប់ការធ្វើវិភាគរកជំងឺបង្កដោយវីរុស និងធ្វើបច្ចុប្បន្នភាពតាមការវិវឌ្ឍន៍នៃតេស្ត
- រៀបចំឯកសារ និងបណ្តុះបណ្តាលវិធីសាស្ត្រធ្វើរោគវិនិច្ឆ័យជំងឺបង្កដោយវីរុស និងវិធីសាស្ត្រយកវត្ថុវិភាគ
- ត្រួតពិនិត្យ និងវាយតម្លៃដំណើរការរបស់មន្ទីរពិសោធន៍វីរុសសាស្ត្រ
- ផ្តល់សេវាកម្មធ្វើរោគវិនិច្ឆ័យជំងឺបង្កដោយវីរុស
- សហការជាមួយមន្ទីរពិសោធន៍នានា អង្គការជាតិ អង្គការអន្តរជាតិ អង្គភាព និងស្ថាប័នពាក់ព័ន្ធការងារស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ
- សម្របសម្រួល ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់សម្រាប់ការអនុញ្ញាតលើសំណើសុំ បង្កើតមន្ទីរពិសោធន៍សុខភាពសត្វ និងផលិតកម្មសត្វ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ជូន។

៦.៦-មន្ទីរពិសោធន៍បាក់តេរីសាស្ត្រ និងមីកូសាស្ត្រ ៖

- ចូលរួមរៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាការងារធ្វើរោគវិនិច្ឆ័យជំងឺបង្កដោយបាក់តេរី និងជំងឺបង្កដោយពពួកមីកូ និងភាពស៊ាំរបស់វាទៅនឹងបសុឱសថ
- ធ្វើរោគវិនិច្ឆ័យជំងឺបង្កដោយបាក់តេរី និងពពួកមីកូ
- សិក្សា ពិសោធ ស្រាវជ្រាវភាពស៊ាំរបស់សត្វទៅនឹងជំងឺបង្កដោយបាក់តេរី និងពពួកមីកូ
- សិក្សា ពិសោធ ស្រាវជ្រាវភាពស៊ាំរបស់បាក់តេរី និងពពួកមីកូទៅនឹងបសុឱសថ
- អនុវត្តកម្មវិធីវិភាគ ព្យាសកម្ម (calibration) និងប្រៀបធៀបលទ្ធផលជាមួយមន្ទីរពិសោធន៍យោង (Reference Lab) ជាតិ តំបន់ និងអន្តរជាតិ
- រៀបចំមន្ទីរពិសោធន៍ស្របតាមស្តង់ដារ ISO មន្ទីរពិសោធន៍
- រៀបចំ ចងក្រងបមាណីយនីតិវិធីប្រតិបត្តិ (SOP) សម្រាប់ការធ្វើវិភាគរកជំងឺបង្កដោយបាក់តេរី និងពពួកមីកូ និងធ្វើបច្ចុប្បន្នភាពតាមការវិវឌ្ឍន៍នៃតេស្ត
- រៀបចំ ចងក្រងឯកសារ និងបណ្តុះបណ្តាលវិធីសាស្ត្រសិក្សាអំពីភាពស៊ាំរបស់មេរោគទៅនឹងបសុឱសថ
- រៀបចំ ចងក្រងឯកសារ និងបណ្តុះបណ្តាលវិធីសាស្ត្រធ្វើរោគវិនិច្ឆ័យជំងឺបង្កដោយបាក់តេរី និងពពួកមីកូ និងវិធីសាស្ត្រយកវត្ថុវិភាគ
- ត្រួតពិនិត្យ និងវាយតម្លៃដំណើរការរបស់មន្ទីរពិសោធន៍បាក់តេរីសាស្ត្រ និងមីកូសាស្ត្រ
- ផ្តល់សេវាកម្មធ្វើរោគវិនិច្ឆ័យជំងឺបង្កដោយបាក់តេរី និងពពួកមីកូ
- សហការជាមួយមន្ទីរពិសោធន៍នានា អង្គការជាតិ អង្គការអន្តរជាតិ អង្គភាព និងស្ថាប័នពាក់ព័ន្ធការងារស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ
- សម្របសម្រួល ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់សម្រាប់ការអនុញ្ញាតលើសំណើសុំ បង្កើតមន្ទីរពិសោធន៍សុខភាពសត្វ និងផលិតកម្មសត្វ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ជូន។

៦.៧-មន្ទីរពិសោធន៍ប៉ារ៉ាស៊ីតសាស្ត្រ ៖

- រៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាការងារធ្វើរោគវិនិច្ឆ័យជំងឺបង្កដោយប៉ារ៉ាស៊ីត និងភាពស៊ាំរបស់ប៉ារ៉ាស៊ីតទៅនឹងបសុឱសថ
- ធ្វើរោគវិនិច្ឆ័យជំងឺបង្កដោយប៉ារ៉ាស៊ីត និងប្រូតូស្វ័អ៊ែរ
- សិក្សា ពិសោធ ស្រាវជ្រាវប្រសិទ្ធភាពរបស់ថ្នាំទំលាក់ប៉ារ៉ាសិត និងឱសថរុក្ខជាតិក្នុងការកំចាត់ប៉ារ៉ាស៊ីត
- សិក្សា ពិសោធ ស្រាវជ្រាវភាពស៊ាំរបស់សត្វទៅនឹងជំងឺបង្កដោយប៉ារ៉ាស៊ីត និងប្រូតូស្វ័អ៊ែរ
- អនុវត្តកម្មវិធីវិភាគ ព្យាសកម្ម (calibration) និងប្រៀបធៀបលទ្ធផលជាមួយមន្ទីរពិសោធន៍យោង (Reference Lab) ជាតិ តំបន់ និងអន្តរជាតិ
- រៀបចំមន្ទីរពិសោធន៍ស្របតាមស្តង់ដារ ISO មន្ទីរពិសោធន៍



4

- រៀបចំ ចងក្រងបមាណីយនីតិវិធីប្រតិបត្តិ (SOP) សម្រាប់ការធ្វើវិភាគរកជំងឺបង្កដោយប៉ារ៉ាស៊ីត និងប្រូតូសូអ៊ែរ និងធ្វើបច្ចុប្បន្នភាពតាមការវិវឌ្ឍន៍នៃតេស្ត
- រៀបចំ ចងក្រងឯកសារ និងបណ្តុះបណ្តាលវិធីសាស្ត្រធ្វើរោគវិនិច្ឆ័យជំងឺបង្កដោយប៉ារ៉ាស៊ីត និងប្រូតូសូអ៊ែរ និងវិធីសាស្ត្រយកវត្ថុវិភាគ
- ត្រួតពិនិត្យ និងវាយតម្លៃដំណើរការរបស់មន្ទីរពិសោធន៍ប៉ារ៉ាស៊ីតសាស្ត្រ
- ផ្តល់សេវាកម្មធ្វើរោគវិនិច្ឆ័យជំងឺបង្កដោយប៉ារ៉ាស៊ីត និងប្រូតូសូអ៊ែរ
- សហការជាមួយមន្ទីរពិសោធន៍នានា អង្គការជាតិ អង្គការអន្តរជាតិ អង្គភាព និងស្ថាប័នពាក់ព័ន្ធការងារស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ
- សម្របសម្រួល ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់សម្រាប់ការអនុញ្ញាតលើសំណើសុំ បង្កើតមន្ទីរពិសោធន៍សុខភាពសត្វ និងផលិតកម្មសត្វ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ជូន។

៦.៨-មន្ទីរពិសោធន៍រោគសាស្ត្រ ៖

- ចូលរួមរៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាការងារធ្វើរោគវិនិច្ឆ័យរោគសាស្ត្រ
- សិក្សា ពិសោធ ស្រាវជ្រាវពីការវិវត្តន៍នៃជំងឺ
- វិភាគការប្រែប្រួលសរីរាង្គ និងសរីររោគសាស្ត្រ (ante and postmortem)
- ធ្វើរោគវិនិច្ឆ័យជំងឺសត្វដោយផ្អែកលើការវិភាគបម្រែបម្រួលជាលិកា (histopathology)
- អនុវត្តកម្មវិធីវិភាគ ព្យាសកម្ម (calibration) និងប្រៀបធៀបលទ្ធផលជាមួយមន្ទីរពិសោធន៍យោង (Reference Lab) ជាតិ តំបន់ និងអន្តរជាតិ
- រៀបចំមន្ទីរពិសោធន៍ស្របតាមស្តង់ដារ ISO មន្ទីរពិសោធន៍
- រៀបចំ ចងក្រងបមាណីយនីតិវិធីប្រតិបត្តិ (SOP) សម្រាប់ការធ្វើវិភាគ និងធ្វើបច្ចុប្បន្នភាពតាមការវិវឌ្ឍន៍នៃតេស្ត
- រៀបចំ ចងក្រងឯកសារ និងបណ្តុះបណ្តាលវិធីសាស្ត្រធ្វើរោគវិនិច្ឆ័យរោគសាស្ត្រ
- ត្រួតពិនិត្យ និងវាយតម្លៃដំណើរការរបស់មន្ទីរពិសោធន៍រោគសាស្ត្រ
- ផ្តល់សេវាកម្មធ្វើរោគវិនិច្ឆ័យរោគសាស្ត្រ
- សហការជាមួយមន្ទីរពិសោធន៍នានា អង្គការជាតិ អង្គការអន្តរជាតិ អង្គភាព និងស្ថាប័នពាក់ព័ន្ធការងារស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ
- សម្របសម្រួល ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់សម្រាប់ការអនុញ្ញាតលើសំណើសុំ បង្កើតមន្ទីរពិសោធន៍សុខភាពសត្វ និងផលិតកម្មសត្វ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ជូន។

៦.៩-មន្ទីរពិសោធន៍ជីវគីមី និងវិសសាស្ត្រ (toxicology) ៖

- ចូលរួមរៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាការងារវិភាគរកសារធាតុគីមី ជីវគីមី និងសារធាតុពុលនៅក្នុងខ្លួនសត្វ និងក្នុងផលិតផលសត្វ

- សិក្សា វិភាគរកប្រភេទ និងកំម្រិតសារធាតុគីមី ជីវគីមី និងសារធាតុពុលដែលមាននៅក្នុងខ្លួនសត្វ
- សិក្សា វិភាគរកភាកសំណល់សារធាតុគីមី ជីវគីមី និងសារធាតុពុល ដែលមាននៅក្នុងផលិតផលសត្វ
- វិភាគរកកាកសំណល់សារធាតុគីមី និងសារធាតុពុល ដែលជះឥទ្ធិពលលើសុខភាពសត្វ
- ធ្វើរោគវិនិច្ឆ័យរកសារធាតុពុល ភាពមិនប្រក្រតីនៃសារធាតុជីវគីមី និងកង្វះអាហាររូបត្ថម្ភ
- អនុវត្តកម្មវិធីវិភាគ ព្យាសកម្ម(calibration)និងប្រៀបធៀបលទ្ធផលជាមួយមន្ទីរពិសោធន៍យោង (Reference Lab) ជាតិ តំបន់ និងអន្តរជាតិ
- រៀបចំមន្ទីរពិសោធន៍ស្របតាមស្តង់ដារ ISO មន្ទីរពិសោធន៍
- រៀបចំ ចងក្រងបមាណីយនីតិវិធីប្រតិបត្តិ (SOP) សម្រាប់ការវិភាគរកសារធាតុគីមី ជីវគីមី និងសារធាតុពុល និងធ្វើបច្ចុប្បន្នភាពតាមការវិវឌ្ឍន៍នៃតេស្ត
- ត្រួតពិនិត្យ និងវាយតម្លៃដំណើរការរបស់មន្ទីរពិសោធន៍ជីវគីមី និងវិសសាស្ត្រ
- រៀបចំ ចងក្រងឯកសារ និងបណ្តុះបណ្តាលវិធីសាស្ត្រវិភាគរកសារធាតុគីមី ជីវគីមី និងសារធាតុពុល
- ផ្តល់សេវាកម្មវិភាគរកសារធាតុគីមី ជីវគីមី និងសារធាតុពុល
- សហការជាមួយមន្ទីរពិសោធន៍នានា អង្គការជាតិ អង្គការអន្តរជាតិ អង្គភាព និងស្ថាប័នពាក់ព័ន្ធការងារស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ
- សម្របសម្រួល ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់សម្រាប់ការអនុញ្ញាតលើសំណើសុំបង្កើតមន្ទីរពិសោធន៍សុខភាពសត្វ និងផលិតកម្មសត្វ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ជូន។

៦.១០-ស្ថានីយស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល ៖

- ចូលរួមរៀបចំផែនការ កម្មវិធី សកម្មភាព គម្រោងថវិកាការងារពិសោធន៍ ស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល
- សិក្សា ពិសោធ ស្រាវជ្រាវលើការងារចិញ្ចឹមសត្វ និងការបង្កាត់ពូជសត្វ
- សិក្សា ពិសោធ ស្រាវជ្រាវ គុណភាព ប្រសិទ្ធភាពបសុឱសថ និងថ្នាំការពារ (វ៉ាក់សាំង)
- សិក្សា ពិសោធ ស្រាវជ្រាវលើកត្តាផ្សេងៗ ដែលជះឥទ្ធិពលលើការបន្តពូជ និងការលូតលាស់របស់ពូជសត្វ
- សិក្សា ពិសោធ ស្រាវជ្រាវ ដំណាំចំណីសត្វ ធនធានចំណីសត្វ ការរៀបចំរូបមន្តផ្សំចំណី របបចំណីសត្វ និងអាហារូបត្ថម្ភសត្វ
- សហការសិក្សា ពិសោធ ស្រាវជ្រាវលើការងារផលិតកម្ម និងបសុព្យាបាលជាមួយស្ថាប័នស្រាវជ្រាវនានា
- សម្របសម្រួលកម្មសិក្សានានា និងការស្រាវជ្រាវរបស់និស្សិត និងអ្នកស្រាវជ្រាវ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ជូន។

-អនុប្រធានការិយាល័យ អនុប្រធានមន្ទីរពិសោធន៍ អនុប្រធានស្ថានីយ៍ ជាជំនួយការឲ្យប្រធាន ហើយត្រូវបានប្រធានប្រគល់ការងារមួយចំនួនឲ្យទទួលបន្ទុក និងទទួលខុសត្រូវចំពោះមុខប្រធាននូវរាល់សកម្មភាពការងារនោះ ហើយត្រូវចូលរួមជាមួយប្រធានក្នុងការទទួលខុសត្រូវរាល់សកម្មភាពការងារដែលបានអនុវត្ត។

**ប្រការ៨ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៩ ..**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល និងប្រធានអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឧបសម្ព័ន្ធនៃប្រកាសលេខ៣៨១......ប្រក.កសក.ប ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧

# អង្គការលេខរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

## ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន សុខភាពសត្វ និងផលិតកម្មសត្វ

### នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការ

១.ការិ.រដ្ឋបាល និងបុគ្គលិក
២.ការិ.គណនេយ្យ
៣.ការិ.ផែនការ និងស្ថិតិ
៤.ការិ.សហប្រតិបត្តិការ
៥.ការិ.តាមដាន និងវាយតម្លៃ

### នាយកដ្ឋានផលិតកម្មសត្វ

១.ការិ.អភិវឌ្ឍន៍ការចិញ្ចឹមសត្វ
២.ការិ.គ្រប់គ្រងផលិតកម្មចំណីសត្វ
៣.ការិ.ពូជសត្វ និងសេនេទិកសត្វ
៤.ការិ.គ្រប់គ្រងកាកសំណល់សត្វ
៥.ការិ.គ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ
៦.ការិ.អត្តសញ្ញាណកម្មសត្វ

### នាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល

១.ការិ.ត្រួតពិនិត្យអនាម័យបសុព្យាបាល
២.ការិ.ផលិតផលបសុព្យាបាល
៣.ការិ.អង្កេត តាមដាន និងប្រយុទ្ធប្រឆាំងជំងឺសត្វ
៤.ការិ.គ្រប់គ្រងមន្ទីរព្យាបាលសត្វ
៥.ការិ.សត្តឃាតដ្ឋាន និងកែច្នៃ
៦.ការិ.អង្កេត តាមដាន និងប្រយុទ្ធប្រឆាំងជំងឺស៊ូណូស

### នាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម

១.ការិ.ផ្សព្វផ្សាយបច្ចេកទេស
២.ការិ.អភិវឌ្ឍន៍សហគមន៍
៣.ការិ.នីតិកម្ម និងដោះស្រាយវិវាទ
៤.ការិ.ចុះបញ្ជីចំណីសត្វ និងបសុឱសថ
៥.ការិ.ស្រាវជ្រាវ និងអធិការកិច្ច

### វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ

១.ការិ.អេពីដេមីសាស្ត្រ និងវិភាគព័ត៌មាន
២.មន្ទីរពិសោធន៍សេនេទិកពូជសត្វ
៣.មន្ទីរពិសោធន៍បសុឱសថ និងកាកសំណល់បសុឱសថ
៤.មន្ទីរពិសោធន៍គុណភាពចំណីសត្វ
៥.មន្ទីរពិសោធន៍វីរុសសាស្ត្រ
៦.មន្ទីរពិសោធន៍បាក់តេរីសាស្ត្រ និងមីកូសាស្ត្រ
៧.មន្ទីរពិសោធន៍ប៉ារ៉ាសិតសាស្ត្រ
៨.មន្ទីរពិសោធន៍រោគសាស្ត្រ
៩.មន្ទីរពិសោធន៍ជីវគីមី និងវិសសាស្ត្រ (Toxicology)
១០.ស្ថានីយស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ * ព្រះរាជាណាចក្រកម្ពុជា